# មហាភូតិត្ថិគាថា

## (គាថាពោលពីគុណស្ត្រី)



(រាជហង្សពោធិសត្វពោលថា)

យំ ពុទ្ធេហិ ឧបញ្ញាតំ, កោ តំ និន្ទិតុមរហតិ;
មហាភូតិត្ថិយោ នាម, លោកស្មិំ ឧទបជ្ជិសុំ។

(វត្ថុគឺស្ត្រី) ណា ដែលពួកជនអ្នកចម្រើនដោយប្រាជ្ញាបញ្ញត្តហើយ បុគ្គលណាគួរតិះដៀលនូវស្ត្រីនោះបាន ធម្មតាស្ត្រីទាំងឡាយមានគុណច្រើន ហើយកើតឡើងក្នុងលោក (មុនគេ) (ក្នុងបឋមកប្ប ភេទស្ត្រីកើតឡើងមុនភេទបុរស) ។

**ខិឌ្ឌា បណិហិតា ត្យាសុ, រតិ ត្យាសុ បតិដ្ឋិតា;**
**ពីជានិ ត្យាសុ រូហន្តិ, យទិទំ សត្តា បជាយរេ;**
**តាសុ កោ និព្វិទេ បោសោ, បាណមាសជ្ជ បាណិភិ។**

ល្បែងគេតាំងទុកក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរក៏តាំងនៅក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយ (ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះពុទ្ធអរិយសាវក និងស្តេចចក្រពត្តិជាដើម) រមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ គឺពួកសត្វទាំងអស់ តែងកើត (ត្រូវអាស្រ័យស្ត្រីទាំងនោះ) បុរសដូចម្តេច ប្តូរជីវិតដោយជីវិត ហើយគប្បីនឿយណាយក្នុងស្ត្រីទាំងនោះ ។

**មេវ នញ្ញោ សុមុខ, ជីនំ អត្ថេសុ យុញ្ជសិ;**
**តស្ស ត្យជ្ជ ភយេ ជាតេ, ភីតេ ន ជាយតេ មតិ។**

ម្នាលសុមុខៈ អ្នកឯងហ្នឹងហើយ មិនមែនជាអ្នកដទៃ រមែងប្រកបក្នុងប្រយោជន៍ចំពោះពួកស្ត្រី ភ័យកើតឡើងដល់អ្នកក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើងដោយសេចក្តីភ័យ ។

(សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក អសីតិនិបាត មហាហំសជាតក បិដកលេខ ៦១ ទំព័រ ១១៨)

ដោយស.ដ.វ.ថ.